MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧០០...............សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាព ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ. បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១. គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធី នៃការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ស្របតាមមាត្រា៧៦ មាត្រា១០១ និងមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ សំដៅពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ និងការគ្រប់គ្រងទិន្នន័យរបស់អ្នកជាប់ពន្ធ ដើម្បីគាំទ្រដល់ការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រង ប្រមូលពន្ធ ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

### ប្រការ ២. វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៣. និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "**ការចុះបញ្ជីពន្ធដារ**" សំដៅដល់ការចុះបញ្ជីអ្នកជាប់ពន្ធទាំងឡាយ ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២- ពាក្យ "**អ្នកជាប់ពន្ធ**" សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។

៣- ពាក្យ "**អាជីវកម្ម**" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលក្នុងគោលដៅផលិត និងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀតរួមទាំងសកម្មភាពរបស់ ស្ថាប័នឬអង្គការនានាដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

៤- ពាក្យ "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាព របស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬម្តងម្កាល ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

៥- ពាក្យ "**បុគ្គល**" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

៦- ពាក្យ "**ទីចាត់ការសហគ្រាស**" សំដៅដល់ទីកន្លែងគ្រប់គ្រងប្រតិបត្តិការអាជីវកម្មរបស់សហគ្រាស។

៧- ពាក្យ "**ទីកន្លែងប្រកបអាជីវកម្មជាគោលដើម**" សំដៅដល់ទីកន្លែងជាគោលដើមសម្រាប់ផ្គត់ផ្គង់ទំនិញឬសេវារបស់សហគ្រាស។

៨. ពាក្យ “*សាខា*” សំដៅដល់កន្លែងផ្គត់ផ្គង់ទំនិញឬសេវា ដែលមិនមែនជាទីកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់សហគ្រាស។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ ទីកន្លែងណាមួយត្រូវបានចាត់ទុកជាសាខារបស់សហគ្រាសក្នុងករណីដែលទីកន្លែងនោះធ្វើអាជីវកម្មលើសពី ០៦ ខែជាប់គ្នានៃឆ្នាំប្រតិទិន។

## ជំពូកទី២
## នីតិវិធីនៃការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

### ប្រការ ៤.-ការចុះបញ្ជីពន្ធដារ

១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ ជាអាទិ៍មាន÷

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាង សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហគ្រាសសាធារណៈ សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

គ. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ. បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២- បុគ្គលដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ត្រូវបានតម្រូវឱ្យចុះបញ្ជីពន្ធដារស្របតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបរ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវស្នើសុំចុះបញ្ជីទៅតាមទ្រង់ទ្រាយគតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោម÷

ក. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រការនេះ ការចុះបញ្ជីពន្ធដារ ត្រូវធ្វើឡើងតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh ស្របទៅតាមការកំណត់ដូចមានចែងក្នុងអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ បុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្ម នឹងទទួលបានឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជីអាជីវកម្មនេះ។

ខ. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការនេះ ឬបុគ្គលណាមួយដែលមានបំណងចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬមិនអាចធ្វើការចុះបញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន ការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈការបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

៣- រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ-កម្រៃសេវា ដោយបញ្ជាក់កាលបរិច្ឆេទនៃការប្រគល់ទទួលបន្ទាប់ពីបានពិនិត្យឃើញថាសំណុំឯកសារស្នើសុំនោះត្រឹមត្រូវ និង គ្រប់គ្រាន់។ ដោយឡែក ការស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រការនេះ រដ្ឋបាលសារពើពន្ធ ត្រូវបំប្លែងឯកសារ បញ្ចូលព័ត៌មានការស្នើសុំចុះបញ្ជី និងសម្របសម្រួលទូទាត់ប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជីទៅតាមគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh ឱ្យបានរួចរាល់ និងត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជី និងប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជី នៅក្រោយពេលបានទទួលលិខិតជាសារអេឡិចត្រូនិកបញ្ជាក់ការទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។

**ប្រការ ៥.-ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ**

១- អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ មានកាតព្វកិច្ចជូនដំណឹងមករដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរ÷

ក. អាសយដ្ឋាន។

ខ. ទ្រង់ទ្រាយ។

គ. នាមករណ៍។

ឃ. កម្មវត្ថុអាជីវកម្ម ឬសកម្មភាពអាជីវកម្ម។

ង. ការផ្ទេរ ការផ្លាស់ប្តូរម្ចាស់ភាគហ៊ុន។

ច. សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា។

ឆ. ការបញ្ឈប់អាជីវកម្ម។

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធដារ។

ឈ. ព័ត៌មានគណនីធនាគារ។

ញ. ព័ត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិចត្រូនិក។

២- អ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មានណាមួយដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មាន ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់មកនូវឯកសារចុងក្រោយនៃឯកសារបញ្ជាក់ការផ្លាស់ប្តូរព័ត៌មាននោះតែប៉ុណ្ណោះ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១) ចំណែកការផ្លាស់ប្តូរព័ត៌មានសាខា ឬបន្ថែមសាខា អ្នកជាប់ពន្ធត្រូវបំពេញព័ត៌មានសាខាតាមទម្រង់១០១-C និងភ្ជាប់ឯកសារដូចមានកំណត់ក្នុងឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន។

៣- អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ប៉ុន្តែនៅមិនទាន់មានលេខអត្តសញ្ញាណកម្មសារពើពន្ធ តាមទម្រង់ថ្មីដែលរដ្ឋបាលសារពើពន្ធបានកំណត់ ប្រធានឬអ្នកតំណាង ម្ចាស់សហគ្រាសឬអ្នកតំណាង របស់បុគ្គលដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មានដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់១០១)។

៤- តាមការចាំបាច់ ឬនៅពេលដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថា អ្នកជាប់ពន្ធបានប្រើប្រាស់ព័ត៌មានមិនពិត ឬមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ ឬឯកសារក្លែងក្លាយ រដ្ឋបាលសារពើពន្ធអាចអញ្ជើញអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមគេហទំព័រចុះបញ្ជីអាជីវកម្ម មកផ្តល់ព័ត៌មានបន្ថែមឬមកធ្វើបច្ចុប្បន្នភាព។

ក្នុងករណីអ្នកជាប់ពន្ធមិនបានបង្ហាញខ្លួនតាមការអញ្ជើញ របស់រដ្ឋបាលសារពើពន្ធ បុគ្គលនោះនឹងត្រូវដាក់ចូលក្នុងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជីរបស់អគ្គនាយកដ្ឋានពន្ធដារ ហើយការចុះបញ្ជីពន្ធដារនឹងត្រូវបានបដិសេធ និងមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីអាជីវកម្មដទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ។

**ប្រការ ៦.-កម្រៃសេវា ការបង់ពន្ធប៉ាតង់ និងពន្ធប្រថាប់ត្រាលើឯកសារមានលក្ខណៈគតិយុត្ត**

១- កម្រៃសេវាចុះបញ្ជីពន្ធដារ មានដូចខាងក្រោម៖

ក. ០ រៀល សម្រាប់ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ២០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ ដែលបានស្នើសុំចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬអ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច។

គ. ៤០០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ ដែលបានស្នើសុំចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

២- កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌ៣ នៃប្រការ៥ នៃប្រកាសនេះ មានដូចខាងក្រោម៖

ក. ០ រៀល សម្រាប់ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ១០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ ដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬអ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច។

គ. ២០០ ០០០ រៀល សម្រាប់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ ដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ។

៣-កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការនេះ ត្រូវអនុវត្តផងដែរចំពោះ៖

ក. ការស្នើសុំផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងវាក្យខណ្ឌ ក ដល់ វាក្យខណ្ឌ ច នៃកថាខណ្ឌ១ នៃប្រការ៥ នៃប្រកាសនេះ ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញនូវ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬលិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬ លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។

ខ. ការស្នើសុំផ្លាស់ប្តូរព័ត៌មាន ឬបន្ថែមសាខា ដែលរដ្ឋបាលសារពើពន្ធត្រូវផ្តល់ជូនឡើងវិញ ឬផ្តល់ជូនបន្ថែមនូវលិខិតបញ្ជាក់ការចុះបញ្ជីសាខា អ្នកជាប់ពន្ធត្រូវបង់កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានទៅតាមចំនួនសាខានីមួយៗដែលបានស្នើសុំ។

គ. ការស្នើសុំបោះពុម្ពឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬលិខិតបញ្ជាក់ការចុះបញ្ជីសាខា ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែក ការស្នើសុំបោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (កាត) អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវាចំនួន ៥ ០០០ រៀល។

៤- ដើម្បីលើកទឹកចិត្ត និងជំរុញការចុះបញ្ជីអាជីវកម្ម រាល់ការស្នើសុំចុះបញ្ជីដែលមានការតម្រូវឱ្យបង់ពន្ធប៉ាតង់ និងពន្ធប្រថាប់ត្រាលើឯកសារមានលក្ខណៈគតិយុត្ត ត្រូវអនុវត្តដូចខាងក្រោម÷

ក. ពន្ធប៉ាតង់ត្រូវបានតម្រូវឱ្យបង់៥០ (ហាសិប) ភាគរយ នៃប្រាក់ពន្ធប៉ាតង់ត្រូវបង់ប្រចាំឆ្នាំ នៅពេលស្នើសុំចុះបញ្ជីពន្ធដារ ទៅតាមសកម្មភាពអាជីវកម្មនីមួយៗដែលបានស្នើសុំ។

ខ. ពន្ធប្រថាប់ត្រាលើឯកសារមានលក្ខណៈគតិយុត្តស្តីពីការបង្កើតក្រុមហ៊ុន ត្រូវបានលើកលែង។

**ប្រការ ៧.- រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ**

១- អ្នកជាប់ពន្ធអាចទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានដូចមានចែងក្នុងប្រការ៤ និងប្រការ៥ នៃប្រកាសនេះ ក្នុងរយៈពេល ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ។

២- ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារឬការធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលរដ្ឋបាលសារពើពន្ធត្រូវប្រគល់ឱ្យអ្នកជាប់ពន្ធមានដូចខាងក្រោម÷

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (កាត) ឬ/និង
- លិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

ខ. អ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច ដែលជាសហគ្រាសអាជីវកម្ម ឬបុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ(កាត) ឬ/និង
- ប័ណ្ណពន្ធប៉ាតង់ ឬ/និង
- លិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

គ. អ្នកជាប់ពន្ធដទៃទៀត ឬអ្នកជាប់ពន្ធដែលមានកម្រិតផលរបរទាបជាងអ្នកជាប់ពន្ធតូច

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ(កាត)។

៣- ក្រោយពេលទទួលបានការសម្រេចឱ្យចុះបញ្ជីពន្ធដារឬធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធអាចចុះដល់ទីតាំងអ្នកជាប់ពន្ធ ដើម្បីប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ និងពិនិត្យផ្ទៀងផ្ទាត់ចំណុចនិយាមកាទីតាំង ថតរូបទីតាំង និងកត់ត្រាទិន្នន័យទីតាំងផ្សេងៗរបស់អ្នកជាប់ពន្ធចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ ៨.- ការបដិសេធការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ**

ក្នុងករណី បុគ្គលណាមួយដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធដូចមានចែងក្នុងប្រការ៤ និងប្រការ៥ នៃប្រកាសនេះ មិនបានបំពេញព័ត៌មាននិងផ្តល់ឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ

ឬមិនគោរពតាមលក្ខខណ្ឌ តាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ឬជាប់ទាក់ទិននឹងសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតដែលមានជំពាក់បំណុលពន្ធ ឬមិនមានទីលំនៅឬកន្លែងធ្វើអាជីវកម្មជាប់លាប់ ឬកន្លែងធ្វើសកម្មភាពអាជីវកម្មមិនសមស្របនឹងកម្មវត្ថុអាជីវកម្មដែលបានស្នើសុំ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកជាប់ពន្ធ ស្តីពីការបដិសេធចំពោះការស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ក្នុងអំឡុងពេល ៣០ ថ្ងៃយ៉ាងយូរ។

## ជំពូកទី៣
## ការចុះពិនិត្យស្ថានភាពអាជីវកម្ម និងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី

### ប្រការ ៩.-ការចុះពិនិត្យស្ថានភាពអាជីវកម្ម

ក្នុងករណីដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញថាព័ត៌មាននៃការចុះបញ្ជីរបស់អ្នកជាប់ពន្ធមិនច្បាស់លាស់គ្រប់ជ្រុងជ្រោយ រដ្ឋបាលសារពើពន្ធអាចចុះពិនិត្យស្ថានភាពអាជីវកម្ម ដល់ទីតាំងរបស់អ្នកជាប់ពន្ធ ឬអញ្ជើញប្រធានក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាស ឬប្រធានសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកត្រូវទទួលបន្ទុកកិច្ចការពន្ធដារមកផ្តល់ព័ត៌មាន ផ្តល់ឯកសារពាក់ព័ន្ធនានា ឬធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណដោយការចុះហត្ថលេខា ការថតរូប-ស្កេនម្រាមដៃ និងប្រឹក្សាយោបល់ពាក់ព័ន្ធនឹងច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមមធ្យោបាយបច្ចេកវិទ្យាព័ត៌មានផ្សេងៗទៀត។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាភិបាល ម្ចាស់សហគ្រាស ឬប្រធានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណាមួយមិនអាចអញ្ជើញមកបង្ហាញខ្លួនដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធបាន ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឬសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច មកបំពេញកាតព្វកិច្ចជំនួសខ្លួនបាន ឬក្នុងករណីចាំបាច់អាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប-ស្កេនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

### ប្រការ ១០.-ការចុះបញ្ជីពន្ធដារជាឯកតោភាគី

បុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជីហើយពុំបានមកចុះបញ្ជី ឬមិនបានមកចុះបញ្ជីតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីអ្នកជាប់ពន្ធជាឯកតោភាគី។ ក្នុងករណីនេះ រដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងកំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីទទួលបន្ទុកកិច្ចការពន្ធដារ។

### ប្រការ ១១.-បញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី

១- អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី សម្រាប់កត់ត្រាអត្តសញ្ញាណរបស់បុគ្គលណាមួយដែល÷

ក. ជាប់ទាក់ទិននឹង សហគ្រាស សមាគម ឬអង្គការនានា ដទៃទៀត ដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារបដិសេធចំពោះការស្នើសុំចុះបញ្ជីពន្ធដារ ដើម្បីបង្កើតសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតក្នុងគោលបំណងប្រព្រឹត្តិបទល្មើសគេចវេះពន្ធ។

ខ. មានជំពាក់បំណុលពន្ធ ឬជាប់ទាក់ទិននឹងសហគ្រាស សមាគម ឬអង្គការនានា ដទៃទៀត ដែលមានជំពាក់បំណុលពន្ធ។

គ. ខកខានក្នុងការមកបង្ហាញខ្លួន ផ្តល់ព័ត៌មានបន្ថែម និងផ្តល់ឯកសារតម្រូវនានាតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ។

ឃ. ជាប់ទាក់ទិននឹងសហគ្រាស សមាគម ឬអង្គការនានា ដទៃទៀត ដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារចុះបញ្ជីជាឯកតោភាគី ហើយមិនបានផ្តល់កិច្ចសហការបំពេញព័ត៌មាននិងផ្តល់ឯកសារតាមការតម្រូវសម្រាប់ការចុះបញ្ជីពន្ធដារឱ្យបានចប់សព្វគ្រប់។

ង. រដ្ឋបាលសារពើពន្ធមានមូលដ្ឋានច្បាស់លាស់ ជឿជាក់ថាមិនមែនជាបុគ្គលដែលទទួលផលពិតប្រាកដពីអាជីវកម្ម ឬប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬមានចេតនាផ្តល់គំនិតឬជំរុញ ឬជួយជ្រោមជ្រែង ឬអូសទាញអ្នកជាប់ពន្ធឬបុគ្គលម្នាក់ទៀត ឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទល្មើសសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម។

២- អគ្គនាយកដ្ឋានពន្ធដារ ត្រូវចែករំលែកបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី ដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការចូលរួមសហការក្នុងការពិនិត្យនិងសម្រេចផ្តល់ការអនុញ្ញាតចំពោះការស្នើសុំចុះបញ្ជី។

៣- បុគ្គលដែលត្រូវបានដាក់ចូលក្នុងបញ្ជីអវិជ្ជមាននៃការចុះបញ្ជីរបស់អគ្គនាយកដ្ឋានពន្ធដារ នឹងមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីអាជីវកម្មដទៃទៀតតាមគេហទំព័រចុះបញ្ជីអាជីវកម្មឡើយ វៀរលែងតែបុគ្គលនោះបានដោះស្រាយរួចរាល់នូវកាតព្វកិច្ចសារពើពន្ធជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ។

## ជំពូកទី៤
## សិទ្ធិរបស់អ្នកជាប់ពន្ធ និងទោសប្បញ្ញត្តិ

### ប្រការ ១២.‚ សិទ្ធិរបស់អ្នកជាប់ពន្ធ

អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឱ្យពិនិត្យឡើងវិញលើការបដិសេធការចុះបញ្ជីពន្ធដារ ឬការដាក់ចូលក្នុងបញ្ជីអវិជ្ជមានសម្រាប់ការចុះបញ្ជី ឬការលុបចេញពីបញ្ជីពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

### ប្រការ ១៣.‚ ទោសទណ្ឌ

ការមិនបានចុះបញ្ជី ឬការមិនបានជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មានឬមិនបានធ្វើបច្ចុប្បន្នភាពព័ត៌មានឱ្យបានទាន់ពេលវេលាតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ ឬត្រូវបានចុះបញ្ជីជាឯកតោភាគី តាមការតម្រូវដូចមានចែងក្នុងប្រការ៤ ប្រការ៥ និងប្រការ១០ នៃប្រកាសនេះ នឹងត្រូវទទួលរងនូវ ការតម្រូវឱ្យបង់ប្រាក់ពន្ធ កម្រៃសេវាចុះបញ្ជី និងទោសទណ្ឌចំពោះការប្រព្រឹត្តិអំពើរាំងស្ទះក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលដែលត្រូវបានរដ្ឋបាលសារពើពន្ធចុះបញ្ជីជាឯកតោភាគី ដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ ហើយមិនបានមកបំពេញកាតព្វកិច្ចចុះបញ្ជីឱ្យបានរួចរាល់ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងទោសទណ្ឌស្របតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ១៤.- និរាករណ៍**

ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

អគ្គនាយកដ្ឋានពន្ធដារ GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ ១០១ / FORM 101

# ពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

## APPLICATION FORM FOR TAX REGISTRATION / TAXPAYER INFORMATION UPDATE

## I- ភាតព្វកិច្ចចុះបញ្ជី/បច្ចុប្បន្នភាពព័ត៌មាន / OBLIGATION OF REGISTRATION/UPDATE INFORMATION

ស្នើសុំ៖ Apply for:

☐ ចុះបញ្ជីពន្ធដារ Tax registration ▶ សូមបំពេញព័ត៌មាន និងភ្ជាប់ឯកសារទៅតាមផ្នែកនៃទម្រង់ទ្រាយគតិយុត្តនីមួយៗ Please fill out the information and attach the documents required by following each part of the legal form

☐ បច្ចុប្បន្នភាពព័ត៌មាន Information Update ▶ សូមបំពេញព័ត៌មានតាមផ្នែកដែលមានការផ្លាស់ប្តូរ និងភ្ជាប់ឯកសារតាមឧបសម្ព័ន្ធស្តីពីឯកសារតម្រូវសម្រាប់បច្ចុប្បន្នភាពព័ត៌មាន Please fill out the information that have been updated in the relevant sections and attach the documents required by following the "Annex on Requirement Documents for Information Update"

សម្គាល់៖ Note:

| | ទម្រង់ទ្រាយគតិយុត្ត / LEGAL FORM | ផ្នែក/PART |
|---|---|---|
| ☐ | 1. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល /State Institution, Diplomatic Mission, Foreign Consulate, International Organization, Technical Cooperation Agency of Other Governments, Political Party, Association and Non-government Organization | 101-P1 |
| ☐ | 2. ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត) /Limited Company (Private / Public Limited Company) | 101-P2 |
| ☐ | 3. ក្រុមហ៊ុនបរទេស (សាខាក្រុមហ៊ុន/ការិយាល័យតំណាង) /Foreign Company (Branch / Representative Office) | 101-P3 |
| ☐ | 4. ក្រុមហ៊ុនសហកម្មសិទ្ធិ (ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ/មានកម្រិត) /Partnership Company (General Partnership / Limited Partnership Company) | 101-P4 |
| ☐ | 5. សហគ្រាសឯកបុគ្គល និងបុគ្គលប្រកបអាជីវកម្មដទៃទៀត /Sole Proprietorship /Others | 101-P5 |

## II- ព័ត៌មានអ្នកបំពេញពាក្យស្នើសុំ / PREPARER INFORMATION

តើអ្នកមានទំនាក់ទំនងអ្វីជាមួយនឹងបុគ្គលស្នើសុំ? What is your relation to the applicant?

☐ ភ្នាក់ងារ/ផ្សេងៗ Agent/Other ______

☐ ប្រធាន/អ្នកតំណាងស្ថាប័ន Head of Institution/Representative ☐ ម្ចាស់កម្មសិទ្ធិករ/ម្ចាស់ភាគហ៊ុន Owner/Shareholder ☐ ក្រុមប្រឹក្សាភិបាល Board of Directors

លេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (ប្រសិនបើមាន) Physical Person Tax Identification Number (If any) ______

ភេទ Sex ☐ ប្រុស Male ☐ ស្រី Female

គោត្តនាម Last Name ______ នាម First Name ______

អក្សរឡាតាំង (គោត្តនាម-នាម) In Latin (Last-name, First-name) ______

ថ្ងៃខែឆ្នាំកំណើត Date of Birth ______ សញ្ជាតិ Nationality ______

☐ លេខអត្តសញ្ញាណប័ណ្ណ Identification Card Number ☐ លេខលិខិតឆ្លងដែន Passport Number ______

ថ្ងៃខែឆ្នាំផ្តល់ Issued Date ______ ថ្ងៃខែឆ្នាំផុតកំណត់ Date of Expiry ______

ទូរស័ព្ទចល័ត Mobile Phone Number ______ សារអេឡិចត្រូនិក Email Address ______

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី) ឬអាសយដ្ឋាននៅក្រៅប្រទេស
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City) or Oversea Address

35mm
45mm
Min 32mm
Max 36mm
រូបថត PHOTO

ស្នាមមេដៃស្តាំ/ហត្ថលេខា ម្ចាស់ខ្លួន
Signature / Right-thumb Print of owner

☐ ខ្ញុំបាទ/នាងខ្ញុំ សូមធានាអះអាងថា រាល់ព័ត៌មានដែលបានបំពេញ និងឯកសារភ្ជាប់នៅក្នុងពាក្យស្នើសុំនេះពិតជាត្រឹមត្រូវ តាមព័ត៌មាន និងឯកសារភ្ជាប់ ដែលផ្តល់ដោយបុគ្គលស្នើសុំ។ I declare that the information and attached documents provided by the applicant in this application are true and correct.

សម្រាប់មន្ត្រីពន្ធដារ Tax Official use only

☐ លេខសម្គាល់ពាក្យស្នើសុំ Application Number ☐ លេខអត្តសញ្ញាណកម្មសារពើពន្ធ Tax Identification Number (TIN) ______

ឈ្មោះអ្នកទទួល Receiver Name ______ លេខសម្រាប់តាមដានឯកសារ Document Tracking Number ______ កាលបរិច្ឆេទទទួល Date Received ______

សម្រាប់មន្ត្រីពន្ធដារ / Tax Official use only
លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ
Application Number/Tax Identification Number (TIN)

# ស្ថាប័នរដ្ឋ ស្ថាប័នបរទេស គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល / STATE INSTITUTION, FOREIGN INSTITUTION, POLITICAL PARTY, ASSOCIATION AND NON-GOVERNMENT ORGANIZATION

**101-P1**

ឈ្មោះអ្នកទទួល Receiver Name ☐ លេខសម្រាប់តាមដានឯកសារ Document Tracking Number ☐ កាលបរិច្ឆេទទទួល Date Received ☐☐ ☐☐ ☐☐☐☐

## 1- ព័ត៌មានទម្រង់គតិយុត្ត /LEGAL FORM INFORMATION

ទម្រង់គតិយុត្ត: Legal form:

☐ ស្ថាប័នរដ្ឋ State Institution
☐ បេសកកម្មទូត/កុងស៊ុល Diplomatic Mission/Consulate
☐ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលនានា Technical Cooperation Agency of other Government
☐ អង្គការអន្តរជាតិ International Organization
☐ គណបក្សនយោបាយ Political Party
☐ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក Local Non-government Organization
☐ អង្គការមិនមែនរដ្ឋាភិបាលបរទេស Foriegn Non-government Organization
☐ សមាគម Association

ផ្សេងៗ Others

## 2- ព័ត៌មានស្ថាប័ន /INSTITUTION INFORMATION

ឈ្មោះជាភាសាខ្មែរ Name in Khmer

ឈ្មោះជាភាសាអង់គ្លេស Name in English

សកម្មភាព/បេសកកម្ម ជាភាសាខ្មែរ Activity/Mission in Khmer

សកម្មភាព/បេសកកម្ម ជាភាសាអង់គ្លេស Activity/Mission in English

ទូរស័ព្ទចល័ត Mobile Phone Number | ទូរស័ព្ទលើតុ Office Telephone Number | សារអេឡិចត្រូនិក Email Address

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី)
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City)

និយាមកាភូមិសាស្ត្រ-រយៈទទឹង Geographical Coordinates-Latitude | រយៈបណ្តោយ Longitude

អាសយដ្ឋាននេះជាកម្មសិទ្ធិ ឬជួល? Is this above address an owned or rented property? ☐ កម្មសិទ្ធិ Owned ☐ ជួល Rented ▶ ថ្លៃឈ្នួលក្នុងមួយខែ Total Monthly Fees ____ រៀល KHR

ចំនួនមន្ត្រី ឬនិយោជិត Number of Officers/Employees | ប្រាក់បៀវត្សសរុប Total Monthly Salary ____ រៀល KHR

## 3- ព័ត៌មានប្រធានស្ថាប័ន ឬអ្នកតំណាង /HEAD OF INSTITUTION/REPRESENTATIVE

▶ តើព័ត៌មានរូបវន្តបុគ្គលនេះ ដូចនឹងព័ត៌មាននៅចំណុច II-ទម្រង់១០១? Is the physical person's information the same as the information provided in section II-Form 101? ☐ ដូច បន្តទៅចំណុចទី ៣.១ Yes, Please skip to section 3.1 ☐ មិនដូច បំពេញព័ត៌មានខាងក្រោម No, Please fill out information below

លេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (ប្រសិនបើមាន) Physical Person Tax Identification Number (If any) | ភេទ Sex ☐ ប្រុស Male ☐ ស្រី Female

គោត្តនាម Last Name | នាម First Name

អក្សរឡាតាំង (គោត្តនាម-នាម) In Latin (Last-name, First-name)

ថ្ងៃខែឆ្នាំកំណើត Date of Birth ☐☐ ☐☐ ☐☐☐☐ | សញ្ជាតិ Nationality

☐ លេខអត្តសញ្ញាណប័ណ្ណ Identification Card Number ☐ លេខលិខិតឆ្លងដែន Passport Number

ថ្ងៃខែឆ្នាំផ្តល់ Issued Date ☐☐ ☐☐ ☐☐☐☐ | ថ្ងៃខែឆ្នាំផុតកំណត់ Date of Expiry ☐☐ ☐☐ ☐☐☐☐

ទូរស័ព្ទចល័ត Mobile Phone Number | សារអេឡិចត្រូនិក Email Address

រូបថត PHOTO (35mm × 45mm; Min 32mm, Max 36mm)

ហត្ថលេខា/ស្នាមមេដៃស្តាំ សាមីខ្លួន Signature / Right-thumb Print of owner

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី) ឬអាសយដ្ឋានក្រៅប្រទេស
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City) or Oversea Address

ឈ្មោះអ្នកទទួល
Receiver Name

លេខសម្រាប់តាមដានឯកសារ
Document Tracking Number

លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ
Application Number/Tax Identification Number (TIN)

**101-P1**

### 3.1 តួនាទីនៅក្នុងស្ថាប័ន /Position in institution:

បញ្ជាក់ /Note: ប្រធានស្ថាប័ន/សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានចាត់ទុកជាអ្នកទទួលបន្ទុកកិច្ចការពន្ធដារ (ប្រសិនបើគ្មានការផ្ទេរសិទ្ធិ ឱ្យបុគ្គលណាមួយ)
The Head of institution/association and non-government organization is the assigned person in charge of tax matters (If there is no designation of an authorized representative)

អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ត្រូវបានតម្រូវឱ្យមកបង្ហាញខ្លួននៅរដ្ឋបាលសារពើពន្ធ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ខ្លួន និងរាល់ព័ត៌មានផ្សេងៗទៀត
Person in charge of tax matters is required to present oneself to the tax administration to verify his/her identity and other information

☐ ប្រធាន/នាយក Head/Director ☐ អ្នកតំណាង/ផ្សេងៗ Representative/Other ☐ អ្នកតំណាងនីតិបុគ្គល Legal Person Representative

ឈ្មោះជាភាសាខ្មែរ
Name in Khmer

ឈ្មោះជាភាសាអង់គ្លេស
Name in English

អត្តលេខក្រុមហ៊ុន
Registration Number

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN)

ទូរស័ព្ទចល័ត
Mobile Phone Number

ទូរស័ព្ទលើតុ
Office Telephone Number

សារអេឡិចត្រូនិក
Email Address

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី) ឬអាសយដ្ឋានក្រៅប្រទេស
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City) or Oversea Address

## 4- ព័ត៌មានសម្រាប់កំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ /TAXPAYER CLASSIFICATION INFORMATION

ឆ្នាំជាប់ពន្ធ Tax Year ចាប់ពី From ដល់ To

ចំនួននិយោជិកសរុប
Total Number of Employees — នាក់ Person(s)

ប្រាក់ខែសរុប
Total Monthly Salary — រៀល KHR

ស្លាកយីហោ (ប្រសិនបើមាន)
Signage Board (If any)

សូមជ្រើសចំណាត់ថ្នាក់អ្នកជាប់ពន្ធ /Please choose type of taxpayer:

☐ អ្នកជាប់ពន្ធធំ Large taxpayer ☐ អ្នកជាប់ពន្ធមធ្យម Medium taxpayer ▶ មិនត្រូវបានតម្រូវឱ្យបង់ពន្ធប៉ាតង់ Not required to pay Patent Tax

## 5- ព័ត៌មានការចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ /REGISTRATION INFORMATION WITH RELEVANT MINISTRY-INSTITUTION

▶ សូមបំពេញព័ត៌មានខាងក្រោម ប្រសិនបើបានចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ៖
Please fill out the following information, if have registered with relevant ministry-institution:

ក្រសួង-ស្ថាប័ន
Ministry-Institution

លេខលិខិត/អត្តលេខចុះបញ្ជី
Registration Number

កាលបរិច្ឆេទចុះបញ្ជី
Date of Registration

## 6- ព័ត៌មានបន្ថែម ប្រាក់ពន្ធ និងកម្រៃសេវាសាធារណៈ /ADDITIONAL INFORMATION, TAX PAYMENT AND PUBLIC SERVICE FEES

▶ ករណីមានព័ត៌មានបន្ថែមសូមបំពេញព័ត៌មានទៅតាមទម្រង់នីមួយៗ ដូចខាងក្រោម៖
In case there is any additional information, please fill out the information following each form below:

- ទម្រង់ព័ត៌មានគណនីធនាគារ (101-A)
  BANK ACCOUNT INFORMATION FORM (101-A)
- ទម្រង់ព័ត៌មានរូបវន្តបុគ្គល (101-B)
  PHYSICAL PERSON INFORMATION FORM (101-B)
- ទម្រង់ព័ត៌មានសាខា (101-C)
  BRANCH INFORMATION FORM (101-C)
- ទម្រង់ព័ត៌មានបេសកកម្ម/សកម្មភាពអាជីវកម្ម (101-D)
  MISSION/BUSINESS ACTIVITY INFORMATION FORM (101-D)

| ឈ្មោះអ្នកទទួល<br>Receiver Name | លេខសម្រាប់តាមដានឯកសារ<br>Document Tracking Number | លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ<br>Application Number/Tax Identification Number (TIN) | **101-P1** |
|---|---|---|---|
| | | | |

▶ សូមមើលតារាងឧបសម្ព័ន្ធស្តីពីកម្រៃសេវាសាធារណៈនិងពន្ធប៉ាតង់ សម្រាប់បំពេញព័ត៌មានខាងក្រោម៖
Please refer to the "Annex on Public Service Fees and Patent Tax" to fill out the information below:

| ល.រ<br>No. | បរិយាយ<br>Description | ទឹកប្រាក់ (រៀល)<br>Amount (KHR) | ឯកតា<br>Unit | ទឹកប្រាក់សរុប (រៀល)<br>Total Amount (KHR) |
|---|---|---|---|---|
| 1 | ប្រាក់ពន្ធប៉ាតង់ (ប្រសិនបើមាន)<br>Patent Tax (If any) | | | |
| 2 | កម្រៃសេវាចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មាន<br>Tax registration and information update fees | | | |
| | | | សរុបរួម<br>Grand Total | |

## 7- បញ្ជីឯកសារភ្ជាប់ / LIST OF ATTACHMENTS

| | បរិយាយ<br>Description | ចំនួន<br>Number |
|---|---|---|
| ☐ | 1. លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ<br>Confirmation of Registration Letter or Permit Letter issued by The Royal Government or relevant ministries/institutions | |
| ☐ | 2. លក្ខន្តិកៈ ឬអនុស្សរណៈជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ (ប្រសិនបើមាន)<br>Memorandum and Article of Association, Memorandum of Understanding with relevant ministries/institutions (If any) | |
| ☐ | 3. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់ប្រធានស្ថាប័ន ឬអ្នកតំណាង<br>Valid Cambodian identification card or passport of head of institution or representative<br>* រូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច<br>Physical persons who are subject to fill out their information in this application form, who have different current address from address in Identification Card or Passport, shall enclosed their Family's record or Resident Record or Letter of Resident certified by local authority | |
| ☐ | 4. រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២ សន្លឹក របស់ប្រធានស្ថាប័ន ឬអ្នកតំណាង /Two current photos taken no more than 3 months ago with size 35 x 45 mm and white background of the head of institution or a representative | |
| ☐ | 5. ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមការទីតាំងរបស់ទីស្នាក់ការ ឬទីចាត់ការសហគ្រាស<br>Title deed or rental agreement of the property with the geographical coordinates of the business address<br>* ទីតាំងដែលគ្មានអគារ ឬជាដីទំនេរ ឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ /Business address without a building or vacant land or unusable building in progress of construction is not allowed to use as the registered address unless there is approval from the General Department of Taxation | |
| ☐ | 6. លិខិតជូនដំណឹងស្តីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ /Authorization letter for the person in charge of tax matters<br>* ប្រសិនបើមានអ្នកទទួលបន្ទុកជំនួស /If have any authorized person | |
| ☐ | 7. លិខិតបញ្ជាក់ព័ត៌មានគណនីធនាគារ របស់ស្ថាប័ន ដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនីធនាគារ)<br>Certified letter issued by the bank on the Institution's bank account information (bank confirmation letter or bank statement or bank passbook)<br>* វៀរលែងតែស្ថាប័នរដ្ឋ /Except state institution | |

## សេចក្តីប្រកាស / DECLARATION

ខ្ញុំបាទ/នាងខ្ញុំ សូមធានាអះអាងថា រាល់ព័ត៌មានដែលបានបំពេញ និងឯកសារភ្ជាប់នៅក្នុងពាក្យស្នើសុំនេះពិតជាត្រឹមត្រូវ។
I declare that the information in this application including all attachments is true and correct.

កាលបរិច្ឆេទ / Date ☐☐ ☐☐ ☐☐☐☐

ហត្ថលេខា/ផ្តិតមេដៃស្តាំ និង ឈ្មោះ
Signature/Right-Thumb Print and Name

សម្រាប់មន្ត្រីពន្ធដារ / Tax Official use only
លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ
Application Number/Tax Identification Number (TIN)

# ក្រុមហ៊ុនមូលធន (ក្រុមហ៊ុនឯកជន / មហាជនទទួលខុសត្រូវមានកម្រិត)
# LIMITED COMPANY (PRIVATE/PUBLIC LIMITED COMPANY)

**101-P2**

| ឈ្មោះអ្នកទទួល Receiver Name | | លេខសម្រាប់តាមដានឯកសារ Document Tracking Number | | កាលបរិច្ឆេទទទួល Date Received | |
|---|---|---|---|---|---|

## 1- ព័ត៌មានទម្រង់គតិយុត្ត /LEGAL FORM INFORMATION

ទម្រង់គតិយុត្តៈ
Legal form:

☐ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត Private Limited Company
☐ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត Public Limited Company

## 2- ព័ត៌មានសហគ្រាសអាជីវកម្ម /BUSINESS ENTERPRISE INFORMATION

ឈ្មោះក្រុមហ៊ុនអក្សរខ្មែរ
Company Name in Khmer

ឈ្មោះអក្សរឡាតាំង
Name in Latin

សកម្មភាពអាជីវកម្មជាភាសាខ្មែរ
Business Activity in Khmer

ជាភាសាអង់គ្លេស
Business Activity in English

ទូរស័ព្ទចល័ត Mobile Phone Number | ទូរស័ព្ទលើតុ Office Telephone Number | សារអេឡិចត្រូនិក Email Address

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី)
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City)

និយាមកាភូមិសាស្ត្រ-រយៈទទឹង
Geographical Coordinates-Latitude

រយៈបណ្ដោយ
Longitude

អាសយដ្ឋាននេះជាកម្មសិទ្ធិ ឬជួល?
Is this above address an owned or rented property?

☐ កម្មសិទ្ធិ Owned ☐ ជួល Rented ▶ ថ្លៃឈ្នួលក្នុងមួយខែ Total Monthly Fees ______ រៀល KHR

### ព័ត៌មានដើមទុន ភាគហ៊ុន /Capital, share information:

ប្រភេទភាគហ៊ុនៈ
Type of Shares

☐ តែមួយប្រភេទ Only one type ▶ ចំនួនភាគហ៊ុន Number of Shares

☐ ច្រើនជាងមួយ More than one type ▶ "ក" ចំនួន "A" Number | "ខ" ចំនួន "B" Number | "គ" ចំនួន "C" Number | "ឃ" ចំនួន "D" Number | "ង" ចំនួន "E" Number

ដើមទុនចុះបញ្ជី (ជារៀល) Registered Capital (KHR) ______ រៀល KHR

តម្លៃចារឹកលើប័ណ្ណ (ជារៀល) Par Value (KHR/Share) ______ រៀល KHR

សញ្ជាតិរបស់បណ្ដាម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតសរុបច្រើនជាងគេ
Nationality of the Total Majority Shareholder in voting right:

▶ ☐ ខ្មែរ Khmer ☐ បរទេស Foreign | ចំនួនភាគរយនៃហ៊ុនសរុប Percentage in Total Share ______ %

## 3- ព័ត៌មានម្ចាស់ភាគហ៊ុន/អ្នកតំណាង /SHAREHOLDER/REPRESENTATIVE INFORMATION

▶ តើព័ត៌មានរូបវន្តបុគ្គលនេះ ដូចនឹងព័ត៌មាននៅចំណុច II-ទម្រង់១០១?
Is the physical person's information the same as the information provided in section II-Form 101?

☐ ដូច បន្តរំលងទៅផ្នែកទី៣.១ Yes, Please skip to section 3.1
☐ មិនដូច បំពេញព័ត៌មានខាងក្រោម No, Please fill out information below

លេខអត្តសញ្ញាណកម្មពន្ធរូបវន្តបុគ្គល (ប្រសិនបើមាន)
Physical Person Tax Identification Number (If any)

ភេទ Sex ☐ ប្រុស Male ☐ ស្រី Female




គោត្តនាម Last Name | នាម First Name

អក្សរឡាតាំង (គោត្តនាម-នាម)
In Latin (Last-name, First-name)

ថ្ងៃខែឆ្នាំកំណើត Date of Birth | សញ្ជាតិ Nationality

☐ លេខអត្តសញ្ញាណប័ណ្ណ Identification Card Number ☐ លេខលិខិតឆ្លងដែន Passport Number

ថ្ងៃខែឆ្នាំផ្តល់ Issued Date | ថ្ងៃខែឆ្នាំផុតកំណត់ Date of Expiry

ទូរស័ព្ទចល័ត Mobile Phone Number | សារអេឡិចត្រូនិក Email Address

ហត្ថលេខា/ស្នាមមេដៃស្ដាំ សាមីខ្លួន
Signature / Right-thumb Print of owner

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី) ឬអាសយដ្ឋានក្រៅប្រទេស
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City) or Oversea Address

[illegible]

ឈ្មោះអ្នកទទួល
Receiver Name

លេខសម្រាប់តាមដានឯកសារ
Document Tracking Number

លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ
Application Number/Tax Identification Number (TIN)

**101-P2**

## 3.1 សូមជ្រើសរើសតួនាទីនៅក្នុងក្រុមហ៊ុនដូចខាងក្រោម /Please choose a position in company below:

បញ្ជាក់ /Note: ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានចាត់ទុកជាអ្នកទទួលបន្ទុកកិច្ចការពន្ធដារ (ប្រសិនបើគ្មានការផ្ទេរសិទ្ធិ ឱ្យបុគ្គលណាមួយ)
The Chairman of the board is the assigned person in charge of tax matters (if there is no designation of an authorized representative)
អ្នកទទួលបន្ទុកកិច្ចការពន្ធដារ ត្រូវបានតម្រូវឱ្យមកបង្ហាញខ្លួននៅរដ្ឋបាលសារពើពន្ធ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ខ្លួន និងរាល់ព័ត៌មានផ្សេងៗទៀត
Person in charge of tax matters is required to present oneself to the tax administration to verify his/her identity and other information

☐ អភិបាល Director ☐ ម្ចាស់ភាគហ៊ុន Shareholder ☐ ប្រធានក្រុមប្រឹក្សាភិបាល Chairman of the board ☐ អ្នកតំណាងនីតិបុគ្គល Legal Person Representative

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ
Company Name in Khmer

ឈ្មោះក្រុមហ៊ុនជាឡាតាំង
Company Name in Latin

អត្តលេខក្រុមហ៊ុន
Registration Number

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN)

ទូរស័ព្ទចល័ត
Mobile Phone Number

ទូរស័ព្ទលើតុ
Office Telephone Number

សារអេឡិចត្រូនិក
Email Address

អាសយដ្ឋាន (ឈ្មោះអគារ/ផ្សារ-បន្ទប់/តូប-ជាន់ទី/ច្រកលេខ-អគារ/ផ្ទះលេខ-ផ្លូវ-ភូមិ-ឃុំ/សង្កាត់-ក្រុង/ស្រុក/ខណ្ឌ-ខេត្ត/រាជធានី) ឬអាសយដ្ឋានក្រៅប្រទេស
Address (Building/Market Name-Room/Store No.-Floor/Gate No.-Building/House No.-Street-Village-Commune-City/District-Province/Capital City) or Oversea Address

សញ្ជាតិរបស់បណ្ដាម្ចាស់ភាគហ៊ុន ដែលមានសិទ្ធិបោះឆ្នោតសរុបច្រើនជាងគេ
Nationality of Majority Shareholders who owned the shares that have the voting rights

☐ ខ្មែរ Khmer ☐ បរទេស Foreign

▶ ចំនួនភាគហ៊ុនសរុប
Total Shares %

ប្រភេទភាគហ៊ុន៖
Type of Shares:

☐ តែមួយប្រភេទ Only one type ▶ ចំនួនភាគហ៊ុន Number of Shares

☐ ច្រើនជាងមួយ More than one type ▶ "ក" ចំនួន "A" Number | "ខ" ចំនួន "B" Number | "គ" ចំនួន "C" Number | "ឃ" ចំនួន "D" Number | "ង" ចំនួន "E" Number

## 4- ព័ត៌មានសម្រាប់កំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ /TAXPAYER CLASSIFICATION INFORMATION

ឆ្នាំជាប់ពន្ធ
Tax Year

ចាប់ពី
From

ដល់
To

ចំនួននិយោជិតសរុប
Total Number of Employees

នាក់
Person(s)

ប្រាក់ខែសរុប
Total Monthly Salary

រៀល
KHR

ស្លាកយីហោ (ប្រសិនបើមាន)
Signage Board (if any)

▶ សូមជ្រើសរើសទម្រង់ទ្រាយគតិយុត្តបន្ថែម (ប្រសិនបើមាន)៖
Please choose additional legal form (if any):

☐ សហគ្រាសសាធារណៈ Public company
☐ សហគ្រាសរដ្ឋ State owned company
☐ ក្រុមហ៊ុនចម្រុះរដ្ឋ State-joint venture company
☐ សហគ្រាសវិនិយោគ-គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ Investment Enterprise-Qualified Investment Project

▶ ត្រូវបានចាត់ទុកជាអ្នកជាប់ពន្ធធំ
Classified as a Large taxpayer

ករណីស្នើសុំចុះបញ្ជីថ្មី សូមបំពេញកាលបរិច្ឆេទផ្គត់ផ្គង់ទំនិញ ឬសេវាដំបូង
In case apply for registration, please fill out date of first supplies of goods or services

▶ សូមជ្រើសរើសការប៉ាន់ស្មានផលរបរប្រចាំឆ្នាំ៖
Please choose estimated Annual Turnover:

☐ ផលរបរលើសពី ១០ពាន់លានរៀល
More than 10,000 Million KHR

▶ អ្នកជាប់ពន្ធធំ ត្រូវបង់ពន្ធប៉ាតង់ ២ ៥០០ ០០០ រៀល/សកម្មភាពអាជីវកម្ម
Large taxpayer shall pay Patent Tax 2,500,000 KHR/Business Activity

☐ ផលរបរលើសពី ៤ ០០០លានរៀល ដល់ ១០ពាន់លានរៀល
More than 4,000 Million KHR to 10,000 Million KHR

▶ អ្នកជាប់ពន្ធធំ ត្រូវបង់ពន្ធប៉ាតង់ ១ ៥០០ ០០០ រៀល/សកម្មភាពអាជីវកម្ម
Large taxpayer shall pay Patent Tax 1,500,000 KHR/Business Activity

☐ ផលរបរលើសពី ៧០០លានរៀល ដល់ ៤ ០០០លានរៀល
More than 700 Million KHR to 4,000 Million KHR

▶ អ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ ៦០០ ០០០ រៀល/សកម្មភាពអាជីវកម្ម
Medium taxpayer shall pay Patent Tax 600,000 KHR/Business Activity

## 5- ព័ត៌មានការចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ /REGISTRATION INFORMATION WITH RELEVANT MINISTRY-INSTITUTION

▶ សូមបំពេញព័ត៌មានខាងក្រោម ប្រសិនបើបានចុះបញ្ជីនៅក្រសួង-ស្ថាប័នពាក់ព័ន្ធ៖
Please fill out the following information, if have registered with relevant ministry-institution:

ក្រសួង-ស្ថាប័ន
Ministry-Institution

លេខលិខិត/អត្តលេខចុះបញ្ជី
Registration Number

កាលបរិច្ឆេទចុះបញ្ជី
Date of Registration

ឈ្មោះអ្នកទទួល
Receiver Name

លេខសម្រាប់តាមដានឯកសារ
Document Tracking Number

លេខសម្គាល់ពាក្យស្នើសុំ/លេខអត្តសញ្ញាណកម្មសារពើពន្ធ
Application Number/Tax Identification Number (TIN)

**101-P2**

▶ សូមបំពេញព័ត៌មានស្តីពីសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសៈ
Please fill out the enterprise establishment declaration information:

ចំនួននិយោជិតសរុបជាស្រី Registration Number ______ នាក់ Person(s)
ចំនួននិយោជិតបរទេស Number of Foreign Employees ______ នាក់ Person(s)
▶ ចំនួននិយោជិតបរទេសជាស្រី Number of Female Foreign Employees ______ នាក់ Person(s)

ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ Weekly Day-off
☐ មួយថ្ងៃអាទិត្យ Sunday
☐ មួយថ្ងៃដោយផ្លាស់ប្តូរវេនគ្នា A rotated day-off
☐ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ Saturday and Sunday
☐ រសៀលថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ Saturday afternoon and Sunday

ចំនួនម៉ោងធ្វើការក្នុង១ថ្ងៃ / ១សប្តាហ៍ Number of working hours per day/week ______ ម៉ោង Hours

តើមានប្រភេទគ្រឿងចក្រ និងសម្ភារវត្ថុធាតុដើមអាចបង្កគ្រោះថ្នាក់នៅកន្លែងការងារដែរឬទេ? Are there any hazardous machineries or raw materials in the workplace? ▶ ☐ មាន Yes ☐ មិនមាន No

## 6- ព័ត៌មានបន្ថែម ប្រាក់ពន្ធ និងកម្រៃសេវាសាធារណៈ /ADDITIONAL INFORMATION, TAX PAYMENT AND PUBLIC SERVICE FEES

▶ ករណីមានព័ត៌មានបន្ថែមសូមបំពេញព័ត៌មានទៅតាមទម្រង់នីមួយៗ ដូចខាងក្រោមៈ
In case there is any additional information, please fill out the information following each form below:

- ទម្រង់ព័ត៌មានគណនីធនាគារ (101-A) BANK ACCOUNT INFORMATION FORM (101-A)
- ទម្រង់ព័ត៌មានរូបវន្តបុគ្គល (101-B) PHYSICAL PERSON INFORMATION FORM (101-B)
- ទម្រង់ព័ត៌មានសាខា (101-C) BRANCH INFORMATION FORM (101-C)
- ទម្រង់ព័ត៌មានបេសកកម្ម/សកម្មភាពអាជីវកម្ម (101-D) MISSION/BUSINESS ACTIVITY INFORMATION FORM (101-D)
- ទម្រង់ SMEs TIC ប្រសិនបើសហគ្រាស លោក-លោកស្រី ស្នើសុំផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាទិភាព
Form SMEs TIC, if you request for tax incentive in priority sector

▶ សូមមើលតារាងឧបសម្ព័ន្ធស្តីពីកម្រៃសេវាសាធារណៈនិងពន្ធប៉ាតង់ សម្រាប់បំពេញព័ត៌មានខាងក្រោមៈ
Please refer to the "Annex on Public Service Fees and Patent Tax" to fill out the information below:

| ល.រ No. | បរិយាយ Description | ទឹកប្រាក់ (រៀល) Amount (KHR) | ឯកតា Unit | ទឹកប្រាក់សរុប (រៀល) Total Amount (KHR) |
|---|---|---|---|---|
| 1 | កម្រៃសេវាបម្រុងនាមករណ៍<br>Reservation fees for enterprise name | | | |
| 2 | កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម<br>Business registration fees | | | |
| 3 | ប្រាក់ពន្ធប៉ាតង់<br>Patent Tax | | | |
